# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ..១១៣..អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័ន

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៨/៣៤៦ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីគោលការណ៍រួម នៃការបង្កើតនិងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៨ ស្តីពីការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

## សម្រេច

**មាត្រា ១.-**

បង្កើតក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័ន ក្នុងគោលដៅសម្របសម្រួលការអនុវត្តកម្មវិធី យុទ្ធសាស្ត្រ និងសកម្មភាពកំណែទម្រង់រដ្ឋបាលនៅក្នុងក្រសួង ស្ថាប័នសាមី តាមការចង្អុលទិសរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**មាត្រា ២.-**

ក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័ន ត្រូវស្ថិតនៅក្រោមការដឹកនាំ និងគ្រប់គ្រងរបស់រដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នសាមី ។

ក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័នមានសមាសភាពដូចខាងក្រោម :

- រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ ឬ ឋានៈស្មើក្នុងរចនាសម្ព័ន្ធ ០១ រូប ជាប្រធាន
- អគ្គនាយក/អគ្គនាយករង ឬ អគ្គលេខាធិការ/អគ្គលេខាធិការរង ឬ អគ្គាធិការ/អគ្គាធិការរង ឬ ឋានៈស្មើក្នុងរចនាសម្ព័ន្ធ ០១ រូប ជាសមាជិក
- ប្រធាន/អនុប្រធាននាយកដ្ឋានជំនាញ ឬ ឋានៈស្មើក្នុងរចនាសម្ព័ន្ធ ០១ រូប ជាសមាជិក
- មន្ត្រីជំនាញ ០២ រូប ជាជំនួយការ

**មាត្រា ៣.-**

ក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័ន មានតួនាទី និងភារកិច្ចចម្បងៗដូចខាងក្រោម :

- ទទួលខុសត្រូវចំពោះមុខរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នសាមី ក្នុងការគ្រប់គ្រង និងដឹកនាំគ្រប់ការងារពាក់ព័ន្ធទៅនឹងកម្មវិធី យុទ្ធសាស្ត្រ និងសកម្មភាពកំណែទម្រង់រដ្ឋបាលរបស់ក្រសួង ស្ថាប័ន
- សម្របសម្រួលការងារកំណែទម្រង់រដ្ឋបាលរវាងក្រសួង ស្ថាប័នសាមី ជាមួយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងកំណែទម្រង់តាមវិស័យ